**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ ១៧៩ ស.ន.ល

ថ្ងៃ.៣.១.កើត...ខែ..ផល្គុន.....ឆ្នាំច.. សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី.០៦...ខែ..មីនា....ឆ្នាំ ២០១៩

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដូចខាងក្រោមៈ

១-កញ្ចប់"ក": ការផ្ដល់សេវាគាំទ្របរិក្ខារ SERVER និងផ្គត់ផ្គង់គ្រឿងបន្លាស់

២-កញ្ចប់"ខ": ការស្ដារកកក់ជុំវិញស្ថានីយបូមទឹកល្អក់ភូមិព្រែក ផ្នែកខាងត្បូង ខាងជើង និងតាមបណ្ដោយមាត់ច្រាំងទន្លេខាងលិចអណ្ដូងស្ថានីយបូម

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ (រួមទាំងសេចក្ដីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០សៀល) ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ត្រឹមវេលាម៉ោង ១៦:០០សៀល ក្នុងមួយច្បាប់តម្លៃ ១៦០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើពិគ្រោះថ្លៃគឺ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ កញ្ចប់"ក"វេលាម៉ោង១៦:១០នាទី និងកញ្ចប់"ខ"វេលាម៉ោង១៦:២០នាទី នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យពិគ្រោះថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការពិគ្រោះថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។

អ្នកពិគ្រោះថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត.ជា វិសុទ្ធ**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ